CIPE | CENTER FOR INTERNATIONAL PRIVATE ENTERPRISE

អង្គការទិន្នន័យអំពីការអភិវឌ្ឍ Open Development Cambodia Organization

# ឯកសារទស្សនទាន
# ការបណ្តុះបណ្តាលស្តីពី
# "ការពង្រឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងសហគ្រាសធុនតូចនិងមធ្យមនៅប្រទេសកម្ពុជា តាមរយៈទិន្នន័យបើកទូលាយ និងអក្ខរកម្មឌីជីថល"

ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤

ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី

**អង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី)** គឺជាគេហទំព័រ "ទិន្នន័យបើកទូលាយ"។ គេហទំព័រប្រភេទនេះ គឺជាគេហទំព័រដំបូងគេបង្អស់នៅតំបន់អាស៊ីអាគ្នេយ៍។ ចលនា "ទិន្នន័យបើកទូលាយ" គឺផ្អែកលើការសន្មតដ៏សាមញ្ញមួយគឺថា ទិន្នន័យទាំងឡាយណាដែលត្រូវបានប្រមូលផ្តុំសម្រាប់ប្រយោជន៍សាធារណៈគួរតែដាក់ឱ្យប្រើប្រាស់បានជាសាធារណៈ ដោយគ្មានការដាក់កំហិតឡើយ។ "ព័ត៌មាន" ឬ "ទិន្នន័យ" ទាក់ទងនឹងវិស័យសាធារណៈគួរផ្តល់ឱ្យដោយសេរីដល់គ្រប់ៗគ្នា ដើម្បីប្រើនិងផ្សព្វផ្សាយជាសាធារណៈ។ អូឌីស៊ីមិនលើកស្ទួយ ឬ ផ្សព្វផ្សាយទស្សនៈ របៀបវារៈ ឬ ការលម្អៀងណាមួយ ក្រៅពីការផ្តល់ព័ត៌មានជាសត្យានុម័តអំពីប្រទេសកម្ពុជា និងការអភិវឌ្ឍនៅក្នុងប្រទេសឡើយ។

## អំពីគម្រោង

វិស័យឯកជន អាចពង្រឹងការដឹកនាំតាមបែបប្រជាធិបតេយ្យ តាមរយៈការរាប់បញ្ចូលឱ្យបានទូលំទូលាយចំពោះក្រុមដែលមិនសូវទទួលបានឱកាសនៅក្នុងសង្គម។ ដោយបានស្វែងយល់ពីទិដ្ឋភាពនេះ អូឌីស៊ីបានទទួលបានជំនួយហិរញ្ញវត្ថុពីមជ្ឈមណ្ឌលសម្រាប់សហគ្រាសឯកជនអន្តរជាតិ ដើម្បីអនុវត្តគម្រោង **"ការពង្រឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងសហគ្រាសធុនតូចនិងមធ្យមនៅប្រទេសកម្ពុជា តាមរយៈទិន្នន័យបើកទូលាយ និងអក្ខរកម្មឌីជីថល"**។ គម្រោងនេះមានគោលដៅចំនួន៤ ដូចជា៖ បង្កើនការយល់ដឹងឱ្យកាន់តែប្រសើរអំពីវិស័យឯកជននៅកម្ពុជា និងទិដ្ឋភាពចូលរួមរបស់ស្ត្រី និងជនជាតិដើមភាគតិច, លើកកម្ពស់សិទ្ធិអំណាចស្ត្រី និងជនជាតិដើមភាគតិចក្នុងការធ្វើអាជីវកម្ម, បង្កើតបណ្តុំធនធានចំណេះដឹង សម្រាប់ផ្តល់ការណែនាំដើម្បីចាប់ផ្តើមអាជីវកម្ម, និងចូលរួមចំណែកក្នុងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាស្តែងតាមបរិយាបន្នសង្គម។ នៅពេលបញ្ចប់ គម្រោងនេះនឹងធ្វើបច្ចុប្បន្នភាពនិងប្រមូលរៀបចំច្បាប់ទាក់ទងគ្រប់គ្រងវិស័យឯកជននៅកម្ពុជា។ គម្រោងនេះក៏នឹងបង្កើតកិច្ចសន្ទនាជាមួយនឹងសហគ្រិន ដើម្បីកំណត់ពីតម្រូវការក្នុងការពង្រីកអាជីវកម្មរបស់ពួកគេដោយផ្សារភ្ជាប់នឹងបទប្បញ្ញត្តិនិងបណ្តាញផ្សព្វផ្សាយឌីជីថល។ បន្ថែមពីនេះ គម្រោងក៏នឹងផលិតជាធនធានអប់រំ ដែលសហគ្រិនអាចប្រើជាជំនួយដល់ការអនុវត្តច្បាប់នៅក្នុងដំណើរការអាជីវកម្ម។

## គោលបំណងនៃការបណ្តុះបណ្តាល

ការបណ្តុះបណ្តាលនេះ ផ្តល់ឱ្យអ្នកចូលរួមនូវការយល់ដឹងបន្ថែមអំពីដំណើរការចុះបញ្ជីអាជីវកម្ម ដែលជាគ្រឹះក្នុងការប្រកបអាជីវកម្មផ្លូវការ ការទទួលខុសត្រូវសង្គម និងសក្តានុពលនៃការប្រើប្រាស់ឌីជីថលដោយសុវត្ថិភាព សម្រាប់ការធ្វើអាជីវកម្មឱ្យមានប្រសិទ្ធភាព និងរីកចម្រើន។ បន្ថែមពីនេះ អ្នកចូលរួមមានឱកាសចូលរួមក្នុងកិច្ចពិភាក្សាអំពីស្ថានភាពអាជីវកម្ម និងសំណូមពរឆ្លើយតបនឹងបញ្ហាប្រឈមនៅក្នុងអាជីវកម្មរបស់ខ្លួន។

## លទ្ធផលរំពឹងទុក

បន្ទាប់ពីចូលរួមសកម្មនៅក្នុងការបណ្តុះបណ្តាលនេះ អ្នកចូលរួមនឹងទទួលបានចំណេះដឹងអំពីការចុះបញ្ជីអាជីវកម្ម ការទទួលខុសត្រូវសង្គម និងជំនាញឌីជីថលដែលផ្តោតជាពិសេសចំពោះសហគ្រាសធុនតូចនិងមធ្យម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ចំណេះដឹងនេះនឹងជួយឱ្យពួកគេគោរពតាមបទប្បញ្ញត្តិរបស់វិស័យឯកជន និងចេះប្រើប្រាស់បណ្តាញសង្គម និងបច្ចេកវិទ្យាឌីជីថលដោយសុវត្ថិភាព។ លើសពីនេះ អ្នកចូលរួមមានឱកាសពិភាក្សាលើប្រធានបទផ្សេងៗជាមួយបុគ្គលពាក់ព័ន្ធនៅក្នុងវិស័យ។

## អ្នកចូលរួមគោលដៅ

អ្នកចូលរួមគោលដៅនៅក្នុងការបណ្តុះបណ្តាលនេះ គឺមកពីវិស័យសហគ្រាសធុនតូចនិងមធ្យម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ រួមទាំងស្ត្រី និងជនជាតិដើមភាគតិច ដែលមានអាជីវកម្មនៅក្នុងខេត្តមណ្ឌលគិរី។

## អំពីប្រព័ន្ធផ្សព្វផ្សាយនិងទំនាក់ទំនង

អូឌីស៊ីបានបន្តផ្សព្វផ្សាយបណ្តុំធនធានចំណេះដឹង ទាក់ទងនឹងការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា ដូចជាកញ្ចប់ព័ត៌មានសហគ្រាសធុនតូច និងមធ្យម, ទំព័រសហគ្រាសធុនតូច និងមធ្យម, ឯកសារច្បាប់ពាក់ព័ន្ធ, និងធនធានអប់រំផ្សេងទៀតនៅលើប្រព័ន្ធផ្សព្វផ្សាយរបស់យើង។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់៖

ទំព័រហ្វេសប៊ុក៖ Open Development Cambodia

គេហទំព័រ៖ https://opendevelopmentcambodia.net/

**របៀបវារៈ**

| ម៉ោង | កម្មវិធី | អ្នកសម្របសម្រួល |
|---|---|---|
| 8:00 – 8:30 | ចុះឈ្មោះ | អ្នកចូលរួម |
| 8:30 – 8:35 | សុន្ទរកថាស្វាគមន៍ និងបើកកម្មវិធី | លោក ធី ទ្រី<br>នាយកប្រតិបត្តិ/និពន្ធនាយកនៃអូឌីស៊ី |
| 8:35 – 8:45 | បទបង្ហាញអំពីគម្រោង | លោក ឆេង ភត្រា<br>មន្ត្រីគម្រោងនៃអូឌីស៊ី |
| 8:45 – 10:15 | ដំណើរការចុះបញ្ជីអាជីវកម្ម និងការទទួលខុសត្រូវសង្គមរបស់អាជីវកម្ម | កញ្ញា ស្រី ណាក់<br>ដៃគូអភិវឌ្ឍអាជីវកម្ម និង អ្នកជំនាញផ្នែកទំនួលខុសត្រូវសង្គមរបស់សាជីវកម្ម នៃក្រុមហ៊ុនមេធាវី សរណ |
| 10:15 – 10:30 | សម្រាកទទួលទានអាហារសម្រន់ | អ្នកចូលរួម |
| 10:30 – 12:00 | គន្លឹះសុវត្ថិភាពអ៊ីនធឺណិត | លោក ស៊ីន វិជ្ជរ៉ា<br>មន្ត្រីផ្នែកអភិវឌ្ឍន៍គេហទំព័រ និងព័ត៌មានវិទ្យានៃអូឌីស៊ី |
| 12:00 – 13:30 | សម្រាកទទួលទានអាហារថ្ងៃត្រង់ | អ្នកចូលរួម |
| 13:30 – 15:00 | កិច្ចពិភាក្សានិងចែករំលែកអំពីស្ថានភាពអាជីវកម្ម | អ្នកសម្របសម្រួល និងអ្នកចូលរួម |
| 15:00 – 15:15 | សម្រាកទទួលទានអាហារសម្រន់ | អ្នកចូលរួម |
| 15:15 – 16:45 | ការបង្កើតមាតិកា និងប្រើប្រាស់មុខងារប៊ូស (Boosting) នៅលើបណ្តាញសង្គម | លោក ណៃ ម៉ាណេត<br>ប្រធានផ្នែកទំនាក់ទំនងនៃអូឌីស៊ី |
| 16:45 – 17:00 | សុន្ទរកថាបិទកម្មវិធី | លោក ធី ទ្រី<br>នាយកប្រតិបត្តិ/និពន្ធនាយកនៃអូឌីស៊ី |

***សម្គាល់៖ អ្នករៀបចំសុំរក្សាសិទ្ធិក្នុងការផ្លាស់ប្តូរកម្មវិធី។***